ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៩០.អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបង្កើតគណៈកម្មាធិការជំរុញការដោះស្រាយបញ្ហាវិស័យឯកជន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពី ការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២៧៦ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតខុទ្ទកាល័យឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា១. –

ត្រូវបានបង្កើតគណៈកម្មាធិការជំរុញការដោះស្រាយបញ្ហាវិស័យឯកជន ស្ថិតក្រោមខុទ្ទកាល័យនាយករដ្ឋមន្ត្រី។

គណៈកម្មាធិការជំរុញការដោះស្រាយបញ្ហាវិស័យឯកជន មានសមាសភាពដូចខាងក្រោម៖

១. ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស	ប្រធាន
២. រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី	អនុប្រធាន
៣. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	អនុប្រធាន

៤. អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការ គោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	អនុប្រធាន
៥. អគ្គលេខាធិការនៃគណៈកម្មាធិការវិនិយោគកម្ពុជា	អនុប្រធាន
៦. រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	សមាជិក
៧. រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	សមាជិក
៨. រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់	សមាជិក
៩. រដ្ឋលេខាធិការក្រសួងបរិស្ថាន	សមាជិក
១០. រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍	សមាជិក
១១. រដ្ឋលេខាធិការក្រសួងសាធារណការ និង ដឹកជញ្ជូន	សមាជិក
១២. រដ្ឋលេខាធិការក្រសួងរ៉ែ និង ថាមពល	សមាជិក
១៣. រដ្ឋលេខាធិការក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ	សមាជិក
១៤. រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	សមាជិក
១៥. រដ្ឋលេខាធិការក្រសួងទេសចរណ៍	សមាជិក
១៦. អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ	សមាជិក
១៧. អគ្គនាយករងនៃអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា	សមាជិក

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់នាយករដ្ឋមន្ត្រី។

មាត្រា ២. _

គណៈកម្មាធិការជំរុញការដោះស្រាយបញ្ហាវិស័យឯកជន មានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ, សម្របសម្រួល និង ជំរុញការដោះស្រាយបញ្ហាប្រឈម ឬ សំណូមពររបស់វិស័យឯកជន លើទិដ្ឋភាពច្បាប់ បច្ចេកទេស ឬ ផ្សេងទៀត ដែលស្ថិតក្នុងដែនសមត្ថកិច្ចចម្រុះត្រូវដោះស្រាយដោយអន្តរក្រសួង និង/ឬ អន្តរស្ថាប័ន និង ដែលលើសពីដែនសមត្ថកិច្ច ឬ លទ្ធភាពសម្រេចរបស់គណៈ-កម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, គណៈកម្មាធិការវិនិយោគកម្ពុជា, ក្រុមការងារតាមវិស័យសម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជន នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន និង យន្តការដទៃទៀត រួមទាំងយន្តការក្រុមការងារជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ
- ធ្វើការពិនិត្យ តាមដាន វាយតម្លៃ និង រាយការណ៍ជូននាយករដ្ឋមន្ត្រីចំពោះរាល់បញ្ហាប្រឈម និងសំណូមពរ ដើម្បីជំរុញការដោះស្រាយ និង/ឬ លើកកម្ពស់បរិយាកាសវិនិយោគ និង ធុរកិច្ច
- ដោះស្រាយបញ្ហាប្រឈម ឬ សំណូមពររបស់វិស័យឯកជន តាមករណីនីមួយៗ តាមការបញ្ជាផ្ទាល់ពីសំណាក់នាយករដ្ឋមន្ត្រី
- បំពេញភារកិច្ចដទៃទៀត តាមការសម្រេចរបស់នាយករដ្ឋមន្ត្រី

មាត្រា៣.-

គណៈកម្មាធិការជំរុញការដោះស្រាយបញ្ហាវិស័យឯកជន មានធនធានហិរញ្ញវត្ថុ ក្រោមការគ្រប់គ្រងរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី និង មានសិទ្ធិប្រើប្រាស់ត្រារបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី សម្រាប់បំពេញការកិច្ច។

មាត្រា ៤.-

គណៈកម្មាធិការជំរុញការដោះស្រាយបញ្ហាវិស័យឯកជន មានសិទ្ធិអញ្ជើញតំណាងក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដែលទទួលបានប្រតិភូកម្ម ឬ មានសិទ្ធិសម្រេច ក្នុងនាមប្រធានក្រសួងស្ថាប័ន តាមការចាំបាច់ ដើម្បីចូលរួមបំពេញការកិច្ចរបស់គណៈកម្មាធិការ។

គណៈកម្មាធិការជំរុញការដោះស្រាយបញ្ហាវិស័យឯកជន មានសិទ្ធិអញ្ជើញស្ថាប័នស្រាវជ្រាវ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និង ជំនាញការ ដើម្បីផ្តល់ព័ត៌មាន និង យោបល់នានា ពាក់ព័ន្ធនឹងការបំពេញការកិច្ចរបស់ខ្លួន។

មាត្រា ៥. _

ប្រធានគណៈកម្មាធិការជំរុញការដោះស្រាយបញ្ហាវិស័យឯកជន ទទួលខុសត្រូវរួមក្នុងការដឹកនាំគណៈកម្មាធិការ និង ដឹកនាំកិច្ចប្រជុំ ។ ប្រធានអាចចាត់តាំងអនុប្រធាន ឬ សមាជិកគណៈកម្មាធិការ ដឹកនាំការងារជំនួស ក្នុងករណីចាំបាច់ ឬ ប្រធានអវត្តមាន។

មាត្រា៦.-

គណៈកម្មាធិការជំរុញការដោះស្រាយបញ្ហាវិស័យឯកជន មានលេខាធិការដ្ឋានមួយជាសេនាធិការ។
លេខាធិការដ្ឋាននេះ មានសមាសភាពដូចខាងក្រោម៖

១. នាយករងខុទ្ទកាល័យនាយករដ្ឋមន្ត្រី	ប្រធាន
២. តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	អនុប្រធាន
៣. តំណាងគណៈកម្មាធិការវិនិយោគកម្ពុជា	អនុប្រធាន
៤. តំណាងក្រសួងពាណិជ្ជកម្ម	សមាជិក
៥. តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍	សមាជិក
៦. តំណាងក្រសួងរ៉ែ និងថាមពល	សមាជិក
៧. តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	សមាជិក
៨. តំណាងក្រសួងបរិស្ថាន	សមាជិក
៩. តំណាងក្រសួងទេសចរណ៍	សមាជិក

មាត្រា៧.-

លេខាធិការដ្ឋានគណៈកម្មាធិការជំរុញការដោះស្រាយបញ្ហាវិស័យឯកជន ជើរតួនាទីសម្របសម្រួលផ្នែករដ្ឋបាល និង មានការិយាល័យនៅឧទ្ធក្ការល័យនាយករដ្ឋមន្ត្រី។

លេខាធិការដ្ឋាននេះ មានការកិច្ចដូចខាងក្រោម ៖

- ផ្តល់សេវាគាំទ្រ និង បំពេញការងារ សម្រាប់ប្រក្រតីភាពនៃកិច្ចដំណើរការប្រចាំថ្ងៃ របស់គណៈ-កម្មាធិការជំរុញការដោះស្រាយបញ្ហាវិស័យឯកជន
- ពិនិត្យ វិភាគ និង លើកយោបល់ជូនគណៈកម្មាធិការពិនិត្យសម្រេច ព្រមទាំងសិក្សា និង ប្រមូលធាតុចូលសម្រាប់គណៈកម្មាធិការ ក្នុងការបំពេញការកិច្ចរបស់ខ្លួន
- រៀបចំផែនការសកម្មភាព និង ធ្វើការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តការកិច្ច ព្រមទាំងរៀបចំរបាយការណ៍វឌ្ឍនភាពការងារ
- បំពេញការកិច្ចដទៃទៀតតាមការសម្រេចរបស់ប្រធានគណៈកម្មាធិការ។

មាត្រា៨ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៩.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៩រោច ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែមេសា ឆ្នាំ២០២៤

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ឧទ្ធកាល័យសម្តេចធិបតីនាយករដ្ឋមន្ត្រី
- ឧទ្ធកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ